# សេចក្តីថ្លែងការណ៍រួម

## អង្គការសង្គមស៊ីវិលប្រារព្ធទិវាពលកម្មអន្តរជាតិ លើកទី ១៣៩ ក្រោមប្រធានបទ «រួមគ្នាបន្តអនុវត្តសេរីភាពមូលដ្ឋាន ដើម្បីធានាយុត្តិធម៌សង្គម»

*រាជធានីភ្នំពេញ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៥*

យើងខ្ញុំទាំងអស់គ្នាជាក្រុមសង្គមស៊ីវិល ដូចជា សហភាពសហជីព និងសហព័ន្ធសហជីពឯករាជ្យ អង្គការធ្វើការងារផ្នែកសិទ្ធិស្ត្រី និងការងារ បណ្តាញយុវជន អ្នកប្រកបរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគមន៍មូលដ្ឋាន និងកម្មករនិយោជិតក្នុងវិស័យផ្សេងៗ ដូចមានរាយនាមខាងក្រោម បានរួបរួមគ្នាប្រារព្ធទិវាពលកម្មអន្តរជាតិលើកទី ១៣៩ ក្រោមប្រធានបទ « ***រួមគ្នាបន្តអនុវត្តសេរីភាពមូលដ្ឋាន ដើម្បីធានាយុត្តិធម៌សង្គម***»។

វិស័យការងារនៅតែជាវិស័យចម្បងបំផុតមួយរបស់ប្រទេសកម្ពុជាដែលស្រូបយកកម្លាំងពលកម្មសរុបប្រមាណ ៩,២៣លាននាក់ ក្នុងនោះ ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ និងកាបូប មានកម្មករនិយោជិតបម្រើការងារសរុបប្រមាណ ៩២៥.០០០ នាក់ វិស័យសណ្ឋាគារ ទេសចរណ៍ និងសេវាកម្មប្រមាណ ៦៣០.០០០ នាក់ និងវិស័យសំណង់ប្រមាណជិត ៣ សែននាក់។ បន្ថែមលើនោះ ប្រជាពលរដ្ឋប្រហែល ៦៣ ភាគរយពឹងផ្អែកលើកសិកម្មដើម្បីផ្គត់ផ្គង់ជីវភាព និងបំពេញតម្រូវការផ្នែកសន្តិសុខស្បៀងអាហារ។ លើសពីនេះ ក្នុងឆ្នាំ ២០២៤ ពលករចំណាកស្រុកប្រមាណ ១,៣៨ លាននាក់ បានផ្ញើចំណូលមកគ្រួសាររបស់ពួកគេប្រមាណ ២,៩៥ ពាន់លានដុល្លារអាម៉េរិក ស្មើប្រមាណ ១១ ភាគរយ នៃចំណូលសរុបប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋ (GDP)។ យោងតាមការវាយតម្លៃរបស់មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) ក្នុងឆ្នាំ ២០២៤ ពលករចំណាកស្រុកមួយនាក់បានបែង ចែកចំណូលទាំងនោះទៅកាន់សមាជិកគ្រួសារយ៉ាងហោចណាស់ពី ២ ទៅ ៣ នាក់។

ការទទួលបានកំណើនប្រាក់ចំណូលខ្ពស់របស់ប្រទេសកម្ពុជា គឺបានមកពីការប្រឹងប្រែងធ្វើការងាររបស់កម្មករនិយោជិតក្នុងវិស័យទាំងនោះ តែទោះជាយ៉ាងនេះក្តី កម្មករនិយោជិតទទួលបានប្រាក់ឈ្នួលទាប។ ជាងនេះទៀត កម្មករក្នុងវិស័យខ្លះ ដូចជា សំណង់ ទេសចរណ៍ សេវាកម្ម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធជាដើមនៅតែស្ថិតក្រៅក្របខ័ណ្ឌប្រាក់ឈ្នួលអប្បបរមាដែលកំណត់ដោយរដ្ឋាភិបាល ដែលនេះធ្វើឱ្យពួកគេងាយប្រឈមនឹងការកេងប្រវ័ញ្ច។ វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ និងកាបូប គឺជាវិស័យតែមួយគត់ដែលមានការកំណត់ប្រាក់ឈ្នួលអប្បបរមា តែយ៉ាងណានេះក្តី ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យនេះ មានកម្រិតទាបមិនឆ្លើយតបទៅនឹងការកើនឡើង យ៉ាងឆាប់រហ័សនៃតម្លៃទំនិញនៅលើទីផ្សារឡើយ។ ក្នុងឆ្នាំ២០២៥ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ និងកាបូប ត្រូវបានដំឡើងត្រឹមតែ ២០៨ ដុល្លារអាម៉េរិកប៉ុណ្ណោះ ដែលនៅមានគម្លាតខ្លាំងជាមួយនឹងរបាយការណ៍របស់សម្ព័ន្ធប្រាក់ឈ្នួលអាស៊ី ដែលបានបង្ហាញថា ប្រាក់

ឈ្នួល សម្រាប់ជីវភាពសមរម្យនៅកម្ពុជា គឺប្រមាណ ៦៤៤.១២ ដុល្លារអាម៉េរិក ឬស្មើប្រមាណ ២.៦៤១.៨៩០. ៨៦ រៀល។

កម្មករនិយោជិត ជាពិសេស កម្មការិនីនៅតែប្រឈមបញ្ហានៅកន្លែងការងារ ដូចជា កិច្ចសន្យាការងារមានថិរវេលាខ្លី សម្ពាធការងារត្រូវបំពេញតាមបរិមាណផលិតកម្ម លក្ខខណ្ឌការងារមិនសមរម្យ ការប្រឈមនឹងបញ្ហាសុខភាពដោយសារការសាយភាយនៃសារធាតុគីមីនៅរោងចក្រ កម្តៅខ្លាំង អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន ការរើសអើងពីនិយោជក កង្វះទារកដ្ឋាននៅកន្លែងការងារ ព្រមទាំងការគំរាមបញ្ឈប់ពីការងារដោយពុំត្រឹមត្រូវ។ នៅពេលកម្មករលើកឡើងអំពីករណីទាំងនេះ ជារឿយៗប្រឈមនឹងការព្យាបាទ ដូចជា គំរាមដោយពាក្យសម្តី ឬបញ្ឈប់ពីការងារដោយខុសច្បាប់ជាដើម។

លើសពីនោះ កម្មករនិយោជិត និងថ្នាក់ដឹកនាំសហជីពមួយចំនួននៅតែប្រឈមឧបសគ្គក្នុងការអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានរបស់ខ្លួន ដូចជា សេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការបង្កើតសហជីព និងសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី ទោះបីជាសិទ្ធិសេរីភាពទាំងនេះត្រូវបានការពារដោយរដ្ឋធម្មនុញ្ញកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏ដោយ។ កម្មករ និងថ្នាក់ដឹកនាំសហជីពរងការចាប់ខ្លួន និងចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ ឬការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដោយសារតែការអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានទាំងនេះ និងភាពសកម្មនិយមរបស់អ្នកទាំងនោះលើសិទ្ធិការងារ។

នៅក្នុងអំឡុងពេលដំណើរការពិនិត្យជាសកលតាមកាលកំណត់ («យូភីអរ») ជុំទី៣ និងជុំទី៤ របស់ប្រទេសកម្ពុជា និងនៅក្នុងសន្និសីទកំពូលនៃអង្គការពលកម្មអន្តរជាតិនៅទីក្រុងហ្សឺណែវ ក្នុងឆ្នាំ២០២៤ រដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ និងគណៈប្រតិភូមកពីជាង១០០ប្រទេសដែលចូលរួមក្នុងសន្និសីទនោះបានផ្តល់អនុសាសន៍ដល់ប្រទេសកម្ពុជាឱ្យធានាលក្ខខណ្ឌការងារល្អប្រសើរ និងបង្កលក្ខណៈងាយស្រួលដល់ការចុះបញ្ជិការសហជីព ព្រមទាំងធានានូវសិទ្ធិសេរីភាពមូលដ្ឋាន ជាពិសេស សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិធ្វើកូដកម្ម និងឱ្យទម្លាក់ចោលបទចោទ ប្រកាន់ព្រហ្មទណ្ឌលើថ្នាក់ដឹកនាំសហជីព និងកម្មករនិយោជិត ព្រមទាំងបង្កើនកិច្ចការពារដល់ពួកគេ។ តែយ៉ាងណាក្តី រាជរដ្ឋាភិបាលនៅពុំទាន់បានអនុវត្តតាមអនុសាសន៍ទាំងនោះឱ្យបានពេញលេញនៅឡើយ ហើយកម្មករនិយោជិតនៅក្នុងវិស័យនានា រួមទាំងសេដ្ឋកិច្ចក្រៅប្រព័ន្ធផង នៅពុំទាន់ទទួលបានការគោរព ការពារ និងលើកម្ពស់ឱ្យបានប្រសើរស្របតាមការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនៅឡើយ។

ទោះបីជាកិច្ចព្រមព្រៀងពាណិជ្ជកម្មមានឥទ្ធិពលខ្លាំងលើសេដ្ឋកិច្ចជាតិ និងជីវភាពរបស់កម្មករនិយោជិតក្តី ប៉ុន្តែទន្ទឹមហ្នឹងកំណើនសេដ្ឋកិច្ចនោះ ក៏ត្រូវតែការពារដល់សិទ្ធិការងារ និងសិទ្ធិមនុស្សជាមូលដ្ឋានផងដែរ។ ខណៈដែលប្រទេសកម្ពុជាកំពុងស្វះស្វែងពង្រឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយសហរដ្ឋអាម៉េរិក ដូចជា កិច្ចព្រមព្រៀងពាណិជ្ជកម្មដែលអាចនាំទៅរកការលើកលែងពន្ធ ឬបន្ធូបអត្រាពន្ធលើទំនេញរបស់ប្រទេសកម្ពុជា ការគោរពសិទ្ធិមនុស្ស និងសិទ្ធិការងារ និងការបញ្ឈប់ការធ្វើទុកបុកម្នេញលើសកម្មជនសិទ្ធិការងារ តំណាងកម្មករនិយោជិត និងសហជីព គឺជាចំនុចសំខាន់មួយក្នុងចំណោមចំនុចសំខាន់ផ្សេងទៀត ដែលរាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ និងបញ្ចូលក្នុងវិធីសាស្ត្រក្នុងការចរចា និងដោះស្រាយ។ ទន្ទឹមនេះ រដ្ឋាភិបាលក៏គួរតែស្វែងរកឱកាសក្នុងការជួបចរចាជាមួយគណៈកម្មការអឺរ៉ុបផងដែរអំពី

លទ្ធភាពក្នុងការទទួលបានមកវិញនូវការអនុគ្រោះពន្ធ ២០ ភាគរយក្រោមប្រព័ន្ធអនុគ្រោះពន្ធ «គ្រប់មុខទំនិញលើកលែងសព្វាវុធ-EBA»។ តាមរយៈដំណោះស្រាយអនុម័តនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ទាក់ទងនឹងករណី អង្គការសង់ត្រាល់ សភាអឺរ៉ុបបានគូសបញ្ជាក់អំពីសារៈសំខាន់នៃគោលនយោបាយពាណិជ្ជកម្មដែលផ្អែកលើសិទ្ធិមនុស្ស ព្រមទាំងបានអំពាវ នាវឱ្យគណៈកម្មការអឺរ៉ុប និងរដ្ឋជាសមាជិកពិនិត្យវាយតម្លៃលើការកែប្រែការអនុគ្រោះពន្ធបន្ថែមទៀតលើមុខទំនិញរបស់ ប្រទេសកម្ពុជា ប្រសិនបើលម្ហសេរីភាពរបស់ពលរដ្ឋ និងលទ្ធិប្រជាធិបតេយ្យនៅតែមិនមានភាពល្អប្រសើរ។

ដើម្បីនាំមកនូវវិបុលភាពសេដ្ឋកិច្ចរបស់ប្រទេសជាតិ និងសុខុមាលភាពរបស់កម្មករនិយោជិត និងប្រជាពលរដ្ឋកម្ពុជា នៅក្នុងឱកាសនៃការប្រារព្ធទិវាពលកម្មអន្តរជាតិនេះ យើងខ្ញុំជាក្រុមសង្គមស៊ីវិល មានរាយនាមខាងក្រោម សូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជា សូមមេត្តាពិចារណា និងដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះសំណូមពរ ឬតម្រូវការអាទិភាពចំនួន ១៣ ចំណុច ដូចខាងក្រោម៖

តម្រូវការទី ១៖ ស្តារឡើងវិញនូវលម្ហសេរីភាពជាមូលដ្ឋានរបស់ពលរដ្ឋ ជាពិសេស សេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការជួបជុំ សេរីភាពក្នុងការបង្កើតសហជីព និងបញ្ឈប់ការរំលោភបំពាន និងធ្វើទុក្ខបុកម្នេញដល់សកម្មជនសិទ្ធិការងារ សមាជិក និងថ្នាក់ដឹកនាំសហជីព ក៏ដូចជាអនុវត្តតាមអនុសាសន៍របស់សភាអឺរ៉ុប យន្តការសិទ្ធិមនុស្សនានារបស់អង្គការសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិ ដើម្បីអាចទទួលបាន ការលុបចោលពន្ធ ២០ ភាគរយក្រោមប្រព័ន្ធអនុគ្រោះពន្ធ EBA។

តម្រូវការទី២៖ ជួបពិភាក្សាជាមួយសមាគមនិយោជក និងតំណាងក្រុមហ៊ុនអ្នកបញ្ជាទិញធំៗដើម្បីរកវិធីសាស្ត្រធានាស្ថិរភាពការងារជូនកម្មករ និងការវិនិយោគនៅកម្ពុជា ដោយមានការពិគ្រោះយោបល់ជាមួយសហជីព និង ភាគីពាក់ព័ន្ធ។

តម្រូវការទី៣៖ សម្របសម្រួលកិច្ចចរចារវាងកម្មករ សហជីព និងនិយោជក ឬក្រុមហ៊ុនម៉ាកយីហោក្នុងការដោះស្រាយករណីកេងបន្លំប្រាក់ឈ្នួល និងការមិនផ្តល់អត្ថប្រយោជន៍ផ្សេងៗតាមច្បាប់ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ ១៩ ដោយធានាថាកម្មករនឹងទទួលប្រាក់ឈ្នួល និងអត្ថប្រយោជន៍ដែលពុំទទួលបាន ជាពិសេសក្នុងករណីរោងចក្របញ្ឈប់ប្រតិបត្តិការ។

តម្រូវការទី៤៖ សម្រួលនីតិវិធីក្នុងការចុះបញ្ជីការសហជីពឱ្យមានភាពសាមញ្ញ និងងាយស្រួល ដោយគ្មានការរើសអើង និងបង្កឧបសគ្គ ផ្អែកតាមអនុសាសន៍ផ្តល់ជូនដោយអង្គការពលកម្មអន្តរជាតិ និងយន្តការនានា។

តម្រូវការទី៥៖ ធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីព ដោយពិគ្រោះយោបល់ជាមួយសហជីព និងភាគីពាក់ព័ន្ធផ្សេងៗ និងធានាថាកម្មករនិយោជិតមានសិទ្ធិសេរីភាពពេញលេញក្នុងការបង្កើតសមាគម ឬចូលជាសមាជិកសហជីពអនុលោមតាមបទដ្ឋានការងារអន្តរជាតិ រួមមាន អនុសញ្ញា៨៧ និងអនុសញ្ញា ៩៨ របស់ពលកម្មអន្តរជាតិ និងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា (មាត្រា ៣៦ និងមាត្រា៤២) និងច្បាប់ស្តីពីការងារកម្ពុជា (មាត្រា ២៦៦ និងមាត្រា២៦៧)។

តម្រូវការទី៦៖ ទម្លាក់ចោលបទព្រហ្មទណ្ឌ និងបណ្តឹងនានាប្រឆាំងនឹងថ្នាក់ដឹកនាំសហជីព និងសកម្មជនបរិស្ថានដែលអនុវត្តសិទ្ធិសេរីភាពស្របតាមរដ្ឋធម្មនុញ្ញ និងអនុសញ្ញាស្នូលនៃអង្គការពលកម្មអន្តរជាតិផ្នែកការងារ

ដោយអនុវត្តខ្ជាប់ខ្ជួនតាមអនុសាសន៍ដែលទទួលបានពីយូភីអជុំទី៣ និង ជុំទី៤ របស់ប្រទេសកម្ពុជា រួមទាំងសន្និសីទកំពូលរបស់អង្គការពលកម្មអន្តរជាតិផ្នែកការងារក្នុងឆ្នាំ២០២៤ ។

តម្រូវការទី៧៖ វិនិយោគកញ្ចប់ថវិកាជាតិបន្ថែមទៅលើប្រព័ន្ធកិច្ចគាំពារសង្គម និងពង្រីកវិសាលភាពគ្របដណ្តប់ឱ្យបានពេញលេញទៅដល់កម្មករនៅក្នុងវិស័យសំណង់ សេវាកម្ម សណ្ឋាគារ ចំណីអាហារ កសិកម្ម សេដ្ឋកិច្ចក្រៅ ប្រព័ន្ធ រួមទាំងយុវជន និស្សិត ដោយជំរុញប្រសិទ្ធភាព និងគុណភាពក្នុងការផ្តល់សេវាដែលអាចទុកចិត្ត បាន ដោយគ្មានការរើសអើង មានតម្លាភាព ជាពិសេស សេវាថែទាំសុខភាព ដោយពិនិត្យវាយតម្លៃលើ អ្នកប្រើប្រាស់សេវា និងអ្នកប្រើប្រាស់បេឡាជាតិសន្តិសុខសង្គម។

តម្រូវការទី៨៖ ទទួលស្គាល់ពីតួនាទីសំខាន់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងកៀរគរមូលនិធិពីដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានាដើម្បីទ្រទ្រង់ដល់ប្រតិបត្តិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីធានាប្រសិទ្ធភាពឯករាជ្យភាព និងនិរន្តរភាពក្នុងការដោះស្រាយវិវាទការងារដែលអាចទទួលយកបានពីសំណាក់ភាគីពាក់ព័ន្ធ។

តម្រូវការទី៩៖ បង្កើតគោលនយោបាយ ឬច្បាប់ដើម្បីលើកកម្ពស់សុខភាព និងសុវត្ថិភាពរបស់កម្មករនិយោជិតក្នុងវិស័យផ្សេងៗ ដូចជា កសិកម្ម សេវាកម្ម កម្សាន្ត ជាពិសេស វិស័យសំណង់អនុលោមតាម[ក្រុមប្រតិបត្តិ]របស់អង្គការពលកម្មអន្តរជាតិស្តីពីសុវត្ថិភាព និងសុខភាពក្នុងវិស័យសំណង់។

តម្រូវការទី១០៖កំណែទម្រង់រចនាសម្ព័ន្ធប្រាក់ឈ្នួល និងពង្រីកការកំណត់ប្រាក់ឈ្នួលគោលនៅក្នុងវិស័យផ្សេងទៀត ដូចជា វិស័យទេសចរណ៍ សណ្ឋាគារ និងសំណង់ រួមទាំងជំរុញការសិក្សាពីសេចក្តីត្រូវការផ្នែកសេដ្ឋកិច្ច និងសង្គមដើម្បីកំណត់ប្រាក់ឈ្នួលសមរម្យថ្នាក់ជាតិមួយ។

តម្រូវការទី១១៖ធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតដើម្បីដាក់បញ្ចូលពលករចំណាកស្រុកក្នុងការទទួលបានសិទ្ធិបោះឆ្នោតពីចម្ងាយ និងពង្រីកវិសាលភាពប្រព័ន្ធកិច្ចគាំពារសង្គមសម្រាប់ពលករចំណាកស្រុកកម្ពុជា។

តម្រូវការទី១២៖បង្កើតគោលនយោបាយជាក់លាក់ដើម្បីធានាទីផ្សារនិងតម្លៃសមរម្យសម្រាប់កសិផលក្នុងស្រុកស្របតាមរដ្ឋធម្មនុញ្ញ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិកសិករអន្តរជាតិ រួមទាំងពង្រីកប្រព័ន្ធកិច្ចគាំពារសង្គមដល់កម្មករនៅក្នុងវិស័យកសិកម្ម។

តម្រូវការទី១៣៖ជំរុញ និងលើកទឹកចិត្តដល់សហជីព និយោជក និងក្រុមហ៊ុនម៉ាកយីហោចុះហត្ថលេខាលើកិច្ចព្រមព្រៀងដែលមានបញ្ចូលបទដ្ឋានការងារអន្តរជាតិ និងការអនុវត្តល្អៗ ដូចជា អនុសញ្ញា ១៩០ និងអនុសាសន៍លេខ២០៦ នៃអង្គការពលកម្មអន្តរជាតិ និងគោលការណ៍ណែនាំរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ស្តីពីទំនួលខុសត្រូវធុរកិច្ចសម្រាប់សហគ្រាសពហុជាតិ ដើម្បី ទប់ស្កាត់ និងលុបបំបាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន ព្រមទាំងការរើសអើងគ្រប់ ទម្រង់នៅរោងចក្រ ឬកន្លែងការងារ៕

**ព័ត៌មានបន្ថែម សូមទាក់ទង៖**


១. លោក យុន ចារ៉ូ អ្នកគ្រប់គ្រងកម្មវិធីការងារ នៃ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស
លេខទូរស័ព្ទ៖ ០៩៣ ៥៥៦ ៦៧១

២. លោកស្រី អ៊ូ ទេពផល្លីន ប្រធានសហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា
លេខទូរស័ព្ទ៖ ០១១ ៩៨៤ ៨៨៣

**អង្គការសង្គមស៊ីវិល និងសហគមន៍គាំទ្រសេចក្តីថ្លែងការណ៍រួមនេះ រួមមាន៖**

១. សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
២. សហព័ន្ធសហជីពកម្ពុជា (CATU)
៣. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
៤. សមាគមបណ្តាញយុវជនកម្ពុជា (CYN)
៥. អង្គការសមាគមធាងត្នោត (STT)
៦. អង្គការសមធម៌កម្ពុជា (EC)
៧. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
៨. អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (LICADHO)
៩. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
១០. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
១១. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
១២. អង្គការក្លាហាន (Klahaan)
១៣. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
១៤. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុនណាហ្គាវើលដ៏ (LRSU)
១៥. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
១៦. សមាគមស្ត្រីជនបទដើម្បីក្សេត្របរិស្ថាន (RWAA)
១៧. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
១៨. សម្ព័ន្ធប្រាក់ឈ្នួលអាស៊ី (AFWA)
១៩. សហពន្ធ័សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)
២០. សហព័ន្ធសហជីពឥទ្ធិពលការងារ (FULI)
២១.សហព័ន្ធសហជីពសេរីឯករាជ្យ (FUFI)
២២. សហព័ន្ធសហជីពឯករាជ្យ (INTUFE)
២៣. សហព័ន្ធសហជីពកម្ពុជាឯករាជ្យ (CITUFED)

២៤. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)
២៥. អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍន៍ (PED)
២៦. អង្គការសម្ព័ន្ធភាពដៃគូដើម្បីអភិវឌ្ឍន៍តាម បែបប្រជាធិបតេយ្យ (CPDD)
២៧. សហគមន៍ស្ត្រីក្លាហាន
២៨. សហគមន៍កៅពីរ
២៩. សហគមន៍ពង្រសែនជ័យ
៣០. សហគមន៍ស្នួរសាន្ត
៣១. សហគមន៍ស្ទឹងកំបុត្រ
៣២. សហគមន៍ឆ្មាអើត
៣៣. សហគមន៍ផ្លូវរថភ្លើង
៣៤. សហគមន៍ ថ្មសសាមគ្គី
៣៥. សហគមន៍ ឡ ពាង (កំពង់ឆ្នាំង)
៣៦. សហគមន៍ វាលឥន្ទ្រី
៣៧. សហគមន៍ ថ្នាន់១០០
៣៨. សហគមន៍ដីធ្លី ១៩៧ ឃុំជីខលើ (កោះកុង)
៣៩. បណ្តាញសហគមន៍ព្រៃឡង់
៤០. សហគមន៍អមលាំង (កំពង់ស្ពឺ)
៤១. សហគមន៍ដីធ្លីអណ្តូងត្របែក (ស្វាយរៀង)
៤២. សហគមន៍បុស្សស្នោរ (ត្បូងឃ្មុំ)
៤៣. សហគមន៍ដីធ្លីជីខក្រោម (កោះកុង)
៤៤. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
៤៥. សហគមន៍ដក់ពរ (កំពង់ស្ពឺ)
៤៦. សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)
៤៧. សហគមន៍ជនជាតិភាគតិចកួយ (ព្រះវិហារ)
៤៨. សហគមន៍ជនជាតិដើមភាគតិចកួយឃុំងន (កំពង់ធំ)
៤៩. សហគមន៍ជនជាតិដើមភាគតិចកួយឃុំប្រមេរុ (ព្រះវិហារ)
៥០. សហគមន៍ដីធ្លី (ប៉ៃលិន)
៥១. សហគមន៍ឡពាង (កំពង់ឆ្នាំង)
៥២. សហគមន៍តំបន់ការពារធម្មជាតិឧត្តមស្រែពស់ (កំពង់ស្ពឺ)
៥៣. សហគមន៍ភ្នំក្រោម (សៀមរាប)
៥៤. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)

៥៥. សហគមន៍ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)
៥៦. សហគមន៍រស្មីសាមគ្គី (កំពង់ស្ពឺ)
៥៧. សហគមន៍សាមគ្គីសង្កែពីរមានរិទ្ធិ (ព្រះវិហារ)
៥៨. សហគមន៍ស្រែប្រាំង (ត្បូងឃ្មុំ)
៥៩. សហគមន៍ព្រៃឈើទេសចរណ៍ទឹកធ្លាក់ស្រែអំបិល (កំពង់ឆ្នាំង)
៦០. សហគមន៍ដីធ្លីតានី (សៀមរាប)
៦១. សហគមន៍ត្នោតជុំ (ពោធិ៍សាត់)
៦២. សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ)